ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធនធានទឹក និងឧតុនិយម

លេខ ១៤២ សជណធទឧ

# សេចក្តីជូនដំណឹង

ក្រសួងធនធានទឹក និងឧតុនិយម សូមជម្រាបជូនដល់សាធារណជនឱ្យបានជ្រាបថា បន្ទាប់ពីបានធ្វើការសង្កេត និងតាមដានលើស្ថានភាពធាតុអាកាសរួចមក ឃើញថា កាលពីថ្ងៃទី 22 ខែសីហា ឆ្នាំ 2010 កន្លងទៅ មានប្រព័ន្ធសម្ពាធទាបមួយ ដែលបាន និងកំពុងលាតសន្ធឹងលើអាងទន្លេមេគង្គភាគខាងលើ ក្នុងប្រទេសថៃ និងឡាវ ។ ប្រព័ន្ធសម្ពាធទាបនេះ បានចូលទៅផ្គួបផ្គាជាមួយនឹងវិសម្ពាធមួយ ដែលកំពុងស្ថិតនៅលើសមុទ្រចិនខាងត្បូង ដែលជាកត្តាធ្វើឱ្យវិសម្ពាធនេះ នឹងវិវត្តន៍ទៅជាកូនព្យុះ រួចនឹងធ្វើដំណើរទៅទិសពាយ័ព្យ ដោយឆ្លងកាត់ភាគខាងក្រោមកោះហៃណាំ ឆ្ពោះទៅភាគខាងលើនៃអាងទន្លេមេគង្គ ។

វិសម្ពាធដែលនឹងវិត្តន៍ទៅជាកូនព្យុះនេះ នឹងមានឥទ្ធិពលមកលើព្រះរាជាណាចក្រកម្ពុជា ចាប់ពីថ្ងៃទី 24 ដល់ថ្ងៃទី 26 ខែសីហា ឆ្នាំ 2010 ។ ស្ថានភាពបែបនេះ នឹងបង្កឱ្យមានភ្លៀងធ្លាក់រាយប៉ាយច្រើនទូទាំងប្រទេស ជាពិសេស នៅតំបន់ខ្ពង់រាបភាគឦសាន និងតំបន់ខ្ពង់រាបភាគខាងជើង ដែលអាចបង្កឱ្យមានជំនន់ដោយទឹកភ្លៀង ។ ចំពោះស្ថានភាពទឹកជំនន់ទន្លេមេគង្គវិញ ក៏នឹងបន្តឡើងបន្ថែមទៀត ផងដែរ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមអាជ្ញាធរដែនដី និងប្រជាពលរដ្ឋ ដែលរស់នៅតំបន់ខាងលើ ដូចជា : ខេត្តឧត្តរមានជ័យ សៀមរាប ព្រះវិហារ ក្រចេះ ស្ទឹងត្រែង រតនះគីរី និងខេត្តមណ្ឌលគីរី សូមជ្រាបជាព័ត៌មាន និងមានការប្រុងប្រយ័ត្នខ្ពស់ ព្រមទាំងត្រៀមវិធានការផ្សេងៗជាមុន ចំពោះស្ថានភាពទឹកជំនន់ដែលនឹងអាចកើតមាននេះ ។

ក្រសួងធនធានទឹក និងឧតុនិយមបាន និងកំពុងបន្តតាមដានស្ថានភាពធាតុអាកាស និងទឹកជំនន់ខាងលើ ហើយនឹងធ្វើសេចក្តីជូនដំណឹងបន្ថែមទៀត ក្នុងករណីមានការចាំបាច់ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែសីហា ឆ្នាំ ២០១០

រដ្ឋមន្ត្រី

លឹម គានហោ

អគារលេខ ៤៧ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ ទូរស័ព្ទ / ទូរសារលេខ (៨៥៥ ២៣.៧២៥ ៩៨៩ / (៨៥៥ ២៣.៤២៦ ៣៤៥
# 47 Preah Norodom B V D. Phnom Penh, Fax/Phone: ( 855) 23.725 989 / ( 855 ) 23.426 345 E-mail : mowram@cambodia.gov.kh